ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣✱៧៧៧

សាលាដំបូងខេត្តសៀមរាប
៣៣៣✱៧៧៧

## សាលក្រមមុនអន្តសេចក្តី

លេខ ៤៩ "ឈ" ១៩
ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១
សំណុំរឿងព្រហ្មទណ្ឌលេខ ១០៥០
ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០
សំណុំរឿងស៊ើបសួរលេខ ១១៩២
ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ ៤២៥
ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០ និង ០០នាទី ព្រឹក នៅសាលសវនាការទី ខ ១ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តសៀមរាប

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១០៥០ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] សុគា ភេទស្រី កើតថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៨០ ជនជាតិខ្មែរ កើតនៅ [redacted] ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] មុខរបរបុគ្គលិកអនាម័យមន្ទីរពេទ្យគន្ធបុប្ផាខេត្តសៀមរាប ឪពុកឈ្មោះ [redacted] មុំ (រស់) ម្តាយឈ្មោះ [redacted] លី (រស់) មានកូន០៣នាក់ ទោសពីមុខ គ្មាន ជាទីតិជន ។

ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថា។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

### <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ នៅចំណុចភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឈ្មោះ [redacted] សុគា បាននិយាយលួងលោមមកឈ្មោះ [redacted] ថា សុំបង្វិលប្រាក់ចំនួន ៥,៤០០$ (ប្រាំពាន់បួនរយ) ដុល្លារអាមេរិក ក្នុងរយៈពេល ០១ខែ ដោយសន្យាសងប្រាក់ទៅឲ្យឈ្មោះ [redacted] ថា វិញចំនួន ៥,៦៨០$ (ប្រាំពាន់

ប្រាំមួយរយកៅសិប)ដុល្លារអាមេរិក។ នៅពេលមកសុំបង្វិលប្រាក់ពីឈ្មោះ[redacted]ថា ឈ្មោះ [redacted] សុគា បានយកកាត អេធីអឹម និងសៀវភៅធនាគារ(ធនាគារកម្ពុជាពាណិជ្ជ) ដែលជារបស់ខ្លួនមកប្រគល់ឱ្យឈ្មោះ[redacted]ថា ដើម្បីធានាដល់ការសុំបង្វិលប្រាក់ខាងលើ ធ្វើឱ្យឈ្មោះ[redacted]ថា មានការជឿជាក់ និងព្រមប្រគល់ប្រាក់ឱ្យទៅឈ្មោះ[redacted]សុគា ចំនួន ៥,៤០០$ (ប្រាំពាន់បួនរយ)ដុល្លារអាមេរិក។ លុះដល់កាលកំណត់ដែលឈ្មោះ [redacted] សុគា ត្រូវសងប្រាក់ទៅឱ្យឈ្មោះ [redacted]ថា ស្រាប់តែឈ្មោះ [redacted] សុគា បែរជាគេចវេសមិនព្រមសង និងបានរត់គេចខ្លួនបាត់។ ក្រោយពីមិនព្រមសងប្រាក់ ឈ្មោះ[redacted]ថា បានយកកាត និងសៀវភៅធនាគាររបស់ឈ្មោះ [redacted]សុគា ទៅដកប្រាក់ស្រាប់តែគណនីរបស់ឈ្មោះ [redacted]សុគា ត្រូវបានបិទ ចំណែកឈ្មោះ សាត សុគា បានគេចវេសមិនព្រមសងប្រាក់ទៅឈ្មោះ[redacted] ថា រហូតដល់បច្ចុប្បន្ន។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ២២៦៨ ពស.ព្រស/ឥ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១។

## នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុគា** បានឆ្លើយថា៖ កាលពីអំឡុងឆ្នាំ២០១៦ ខ្លួនបានខ្ចីចងការប្រាក់ឈ្មោះ[redacted] ថា ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក ដោយគិតការប្រាក់ ៥% (ភាគរយ) ក្នុងមួយខែ ហើយខ្លួនបានដាក់បញ្ចាំកាត ATM ដើម្បីឱ្យឈ្មោះ[redacted] ថា បើកការប្រាក់រយៈពេល ០៤ឆ្នាំមកហើយ ទើបសងគ្រប់ចំនួន ក្រោយមកទៀតក្នុងខែឧសភា ឆ្នាំ២០២០ ខ្លួនបានខ្ចីប្រាក់សរុបទាំងអស់ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ដោយដាក់បញ្ចាំកាត ATM សៀវភៅបញ្ជីធនាគារ ដោយគិតការប្រាក់ ចំនួន ៣០០ (បីរយ) ដុល្លារអាមេរិក ក្នុងមួយខែ ខ្លួនបានបង់ការប្រាក់ចំនួន ០៥ខែ គិតពីខែមិថុនា ដល់ខែវិច្ឆិកា ទើបតែខកខានចាប់ពីខែធ្នូ ឆ្នាំ២០២០ ដោយមូលហេតុ កន្លែងធ្វើការខាងមន្ទីរពេទ្យគន្ធបុប្ផាបានបញ្ឈប់ខ្លួនពីការងារដោយបញ្ហាកូវីដ១៩។ ខ្លួនស្នើសុំឱ្យតុលាការដោះលែងខ្លួនឱ្យមានសេរីភាពបានត្រលប់ទៅផ្ទះវិញ ដោយហេតុថាខ្លួនពិតជាបានខ្ចីប្រាក់ពីឈ្មោះ [redacted] ថា ប្រាកដមែន ហើយក៏មានឆន្ទៈក្នុងការសងវិញឱ្យគ្រប់ចំនួនដែរ ម្យ៉ាងទៀតមិនមានចេតនា ក្នុងការគេចវេសក្នុងការកោះហៅឱ្យចូលខ្លួនពីតុលាការនោះទេ។ ខ្លួនសូមសន្យាថានៅពេលដែលត្រឡប់ទៅផ្ទះវិញ និងយកប្រាក់ទៅសងដើមបណ្តឹងវិញឱ្យគ្រប់ចំនួន និងសន្យាចូលមកបង្ហាញខ្លួននៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ខាងមុខនេះ។

-លោកមេធាវី[redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ជនជាប់ចោទពិតជាបានធ្វើកិច្ចសន្យាខ្ចី និងមានឯកសារបញ្ចាំដូចជាកាត ATM (ប្រាក់បៀវត្ស) ពីកូនក្តីរបស់ខ្លួនពិតមែន តែជនជាប់ចោទបានប្តូរកាត ATM (ប្រាក់បៀវត្ស) ថ្មី ហើយមិនបានប្រាប់កូនក្តីខ្លួន បណ្តាលឱ្យកូនក្តីខ្លួនមិនអាចដកប្រាក់បាន។ ហើយម្យ៉ាងទៀតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ រយៈពេល០៥ខែ ចាប់ពីអំឡុងខែមិថុនា ដល់ខែវិច្ឆិកា ឆ្នាំ២០២០ ជនជាប់ចោទមិនបានបន្តសងប្រាក់មកកូនក្តីខ្លួនទៀត នេះជាបទល្មើស ម្យ៉ាងទៀតជនជាប់ចោទមិនបានតម្កល់ប្រាក់តាមចៅក្រមស៊ើបសួរ និងពុំមានអាសយដ្ឋានច្បាស់លាស់។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមកឃើញថាជនជាប់ចោទ មានឆន្ទៈក្នុងការសងប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីវិញហើយ ម្យ៉ាងវិញទៀតជន

ជាប់ចោទក៏មានអាសយដ្ឋានច្បាស់លាស់ហើយដែរ ឃើញថាការឃុំខ្លួនបណ្ដោះអាសន្នពុំមានភាពចាំបាច់ឡើយ ស្នើសុំតុលាការជំនុំជម្រះ មិនឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ក្នុងការសម្រេចជំនុំជម្រះរឿងមុនអង្គសេចក្ដី។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា៖កូនក្ដីខ្លួនពិតជាបានធ្វើកិច្ចសន្យាខ្ចីបរិភោគដោយមានការប្រាក់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ដោយមានកិច្ចសន្យាត្រឹមត្រូវប្រាកដមែន ហើយកូនក្ដីខ្លួនក៏បានសងប្រាក់ទៅវិញជាបន្តបន្ទាប់តាមការកំណត់ហើយដែរ។ ម្យ៉ាងវិញទៀតកូនក្ដីខ្លួនបានបញ្ជាក់ថា ខ្លួនមានឆន្ទៈក្នុងការសងប្រាក់ទៅដើមបណ្ដឹងរដ្ឋប្បវេណីវិញឱ្យគ្រប់ចំនួនផងដែរ។

## សំអាងហេតុ

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថា

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានស្ដាប់ចម្លើយចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងខេត្តសៀមរាប

## យល់ឃើញថា

១.តាមចម្លើយរបស់ជនជាប់ចោទ និងមេធាវីការសិទ្ធិឱ្យជនជាប់ចោទបានលើកឡើងប្រហាក់ប្រហែលគ្នាថា ក្នុងរឿងអង្គហេតុខាងលើនេះជារឿងកិច្ចសន្យាខ្ចីបរិភោគ ដែលកើតឡើងតាំងពីឆ្នាំ២០១៦ រហូតដល់ថ្ងៃកើតហេតុ ហើយមូលហេតុដែលជនជាប់ចោទអាក់ខានក្នុងការសងប្រាក់ទៅដើមបណ្ដឹងរដ្ឋប្បវេណី ដោយហេតុថាមន្ទីរពេទ្យគន្ធបុប្ផាបានបញ្ឈប់ខ្លួនពីការងារ ទើបខ្លួនពុំមានលទ្ធភាពសងប្រាក់ទៅដើមបណ្ដឹងទៀតបាន។ ជនជាប់ចោទ និងមេធាវីការពារសិទ្ធិជនជាប់ចោទ សន្យា និងធានាថានឹងមានវត្តមាននៅអង្គសវនាការ អង្គសេចក្ដីនាពេលខាងមុខនេះ ដោយពុំធ្វើការគេចវេសពីការកោះហៅតុលាការឡើយ ម្យ៉ាងវិញទៀតខ្លួនមានកូនចំនួន០៣នាក់ដែលត្រូវចិញ្ចឹម ហេតុដូច្នេះ ស្នើសុំឱ្យតុលាការដោះលែងឱ្យខ្លួនមានសេរីភាព ដើម្បីរកប្រាក់សងដើមបណ្ដឹងរដ្ឋវេណីវិញ។

២.តាមសេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការក៏បានយល់ឃើញថា ដោយជនជាប់ចោទមានអាសយដ្ឋានច្បាស់លាស់ និងបានសន្យាថានឹងមានវត្តមាននៅពេលសវនាការ អង្គសេចក្ដីខាងមុខ ម្យ៉ាងវិញទៀតរឿងនេះជារឿងកិច្ចសន្យាខ្ចីប្រាក់ ដែលពុំទាន់ដល់ការវែកញែករកឱ្យឃើញនូវពិរុទ្ធភាពនៅឡើយ តំណាងអយ្យការ ស្នើសុំទៅក្រុមជំនុំជម្រះ មិនឃុំខ្លួនជនជាប់ចោទ។

៣.តាមការស្នើសុំរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំឃុំខ្លួនជនជាប់ចោទត្រឹមរយៈពេលគិតត្រឹមពីថ្ងៃនេះរហូតដល់ពេល សវនាការខាងមុខ ដោយខ្លាចជនជាប់ចោទគេចវេស តុលាការយល់ឃើញថាការលើកឡើងនេះ ពុំមានភាពចាំបាច់ តាមការស្នើសុំនេះឡើយ។



Scanned with CamScanner

៤.ផ្អែកតាមការអះអាងខាងលើតុលាការយល់ឃើញថា ការស្នើរបស់ជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងយោបល់តំណាងអយ្យការមានហេតុផលសមរម្យ គប្បីតុលាការលើកយកមកពិចារណាស្រប និងសម្រេចតាមមាត្រា ៣០៣ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះ សាលាដំបូងខេត្តសៀមរាប**

**សម្រេច**

**មិនឃុំខ្លួន ឈ្មោះ** [redacted] **សុគា** ភេទស្រី កើតថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៨០ ជនជាតិខ្មែរ ។

ពីបទ ឆបោក ប្រព្រឹត្តនៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣០៣ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]

---

ថ្ងៃពុធ ៤រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

សៀមរាប,ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]